# កម្ពុជា

| តារាង១៖ សូចនាករម៉ាក្រូសេដ្ឋកិច្ច | 2019 |
|---|---|
| ចំនួនប្រជាជន លាននាក់ | 16.6 |
| ផ.ស.ស បច្ចុប្បន្ន គិតជាប៊ីលានដុល្លារ | 29.3 |
| ផ.ស.ស បច្ចុប្បន្ន ក្នុងម្នាក់ គិតជាដុល្លារ | 1,622.6 |
| អត្រាសិស្សចូលរៀនបឋមសិក្សា (%សរុប) [a] | 107.8 |
| អាយុកាលមធ្យមគិតពីកំណើត ឆ្នាំ [a] | 69.3 |

ប្រភព៖ WDI, Macro Poverty Outlook, and official data.

Note: a. Most recent WDI value (2017).

## សង្ខេប

*សេដ្ឋកិច្ចរបស់កម្ពុជា បានរងការប៉ះទង្គិចយ៉ាងដំណំពីការផ្ទុះវីរុសកូវីឌ-១៩ទូទាំងសាកលលោក។ ការផ្ទុះនេះ បានធ្វើឱ្យម៉ាស៊ីនកំណើនសេដ្ឋកិច្ចធំៗរបស់កម្ពុជា ធ្លាក់ល្បឿនយ៉ាងគំហុកនៅក្នុងត្រីមាសទីមួយ ឆ្នាំ២០២០ ដោយធ្វើឱ្យសកម្មភាពឧស្សាហកម្មទេសចរណ៍ និងសំណង់ ធ្លាក់ចុះខ្សោយយ៉ាងខ្លាំង។ យោងតាមសេណារីយោបន្ទាត់គោលកំណើនក្នុងឆ្នាំ២០២០ ត្រូវបានព្យាករទុកថានឹងថយល្បឿនមកនៅត្រឹម ២,៥ភាគរយ។ ហានិភ័យនានាដែលអាចកើតមាននោះ រួមមាន ការផ្ទុះនៃការឆ្លងជំងឺកូវីឌ-១៩នៅក្នុងប្រទេស, ការអូសបន្លាយនៃការធ្លាក់ចុះចំនួនភ្ញៀវទេសចរ និងការកែសម្រួលស្ថានភាពឡើងវិញរបស់ទីផ្សារអចលនទ្រព្យ។*

## *ស្ថានការណ៍ថ្មីៗ*

ការរាលដាលវីរុសកូវីឌ-១៩ បានអង្រួនពិភពលោកឱ្យរង្គើក្នុងសភាពមួយដែលមិនធ្លាប់មានពីមុនមក ហើយជះការប៉ះទង្គិចយ៉ាងដំណំមកលើសេដ្ឋកិច្ចរបស់កម្ពុជា។ នៅក្នុងឆ្នាំ២០១៩ សេដ្ឋកិច្ចមានកំណើនខ្ពស់ជាក់ស្តែងគឺ៧,១ភាគរយ (គំនូសតាង១) ក៏ប៉ុន្តែ ការផ្ទុះរបស់វីរុសនេះ បានធ្វើឱ្យម៉ាស៊ីនកំណើនសេដ្ឋកិច្ចធំៗរបស់កម្ពុជា ធ្លាក់ល្បឿនយ៉ាងគំហុកនៅដើមឆ្នាំ២០២០នេះ។ ក្នុងឆ្នាំ២០១៩ កំណើនរបស់ការនាំចេញសរុបនៃសម្លៀកបំពាក់ ស្បែកជើង និង ទំនិញសម្រាប់ការធ្វើដំណើរ បានថយចុះមកនៅ១៣,៦ភាគរយ ប្រៀបធៀបទៅនឹង ១៧,៧ភាគរយ ក្នុងឆ្នាំ២០១៨។ ការស្រុតចុះនេះ បណ្តាលមកពីការនាំចេញសរុបនៃសម្លៀកបំពាក់ ស្បែកជើង និង ទំនិញសម្រាប់ការធ្វើដំណើរទៅកាន់ទីផ្សារសហភាពអឺរ៉ុប បានធ្លាក់ចុះ ០,៥ភាគរយ (គំនូសតាង២) ដែលជាការធ្លាក់ចុះលើកដំបូង តាំងពីមានវិបត្តិហិរញ្ញវត្ថុសាកលលោក ឆ្នាំ២០០៨/២០០៩ មកម្លេះ។ ដោយមានអំណោយផលល្អពីការរួចផុតពន្ធគយ និង មិនជាប់កូតាក្នុងការនាំទំនិញចូលទីផ្សារសហរដ្ឋអាមេរិក ការនាំចេញទំនិញសម្រាប់ការធ្វើដំណើរ ត្រូវបានពង្រីកថែមទៀត កើនរហូរដល់ទៅ ១,២៩ប៊ីលានដុល្លារអាមេរិក (កើន ៩៦,៣ភាគរយ) ក្នុងឆ្នាំ២០១៩។

ក្នុងឆ្នាំ២០១៩ កំណើននៃការមកដល់របស់ភ្ញៀវអន្តរជាតិ មានសភាពថមថយបន្តិច គឺកើនបានតែ ៦,៦ភាគរយទេ ប្រៀបធៀបទៅនឹង១០,៧ភាគរយ ក្នុងឆ្នាំ២០១៨។ ចំនួនភ្ញៀវទេសចរទៅទស្សនារមណីយដ្ឋានប្រាសាទអង្គរ ដែលជាទីដៅទេសចរណ៍ដ៏សំខាន់ក្នុងប្រទេស បានថយចុះ ១៤,១ភាគរយ ក្នុងឆ្នាំ២០១៩ ដែល ជាថ្មីម្តងទៀត ជាការធ្លាក់ចុះលើកដំបូងហើយតាំងពីមានវិបត្តិហិរញ្ញវត្ថុសាកលលោកឆ្នាំ២០០៨/២០០៩ ហើយវាបន្តធ្លាក់ ៣៧,២ភាគរយ នៅក្នុងរង្វង់ពីរខែដំបូងនៃឆ្នាំ២០២០នេះ។ នៅក្នុងឆ្នាំ២០១៩ ការរួមចំណែករបស់ផ្នែកសណ្ឋាគារ និងភោជនីយដ្ឋានដល់កំណើនសេដ្ឋកិច្ច បានថយចុះគួរឱ្យកត់សម្គាល់ ហើយរីឯភាគចំណែករបស់ផ្នែកកសិកម្ម ក៏រួញបន្តិចដែរ។ ក្នុងឆ្នាំ២០២០ សកម្មភាពសំណង់ថយសម្ទុះរបស់វា ដោយសារការនាំចូលដែកថែបថយចុះយ៉ាងគំហុក ៤១,៣ភាគរយ ក្នុងខែមករា ឆ្នាំ២០២០ ប្រៀបទៅនឹងមួយឆ្នាំមុន បន្ទាប់ពីតម្លៃរបស់គម្រោងសាងសង់ដែលអនុញ្ញាតរួច បានកើនទ្វេដងក្នុងឆ្នាំ ២០១៩ ដែលកាលនោះ វិស័យសំណង់ (និងអចលនទ្រព្យ) រួមចំណែកបានជាងមួយភាគបីនៃកំណើនសរុបពិត។

ខណៈដែលតម្រូវការចំពោះទំនិញប្រើប្រាស់ ដូចជាស្បៀងអាហារ, ភេសជ្ជៈ និងផលិតផលប្រេង នៅតែមានភាពស្វាហាប់នៅឡើយ អ្នកប្រើប្រាស់ហាក់ដូចជាមិនសូវមានតម្រូវការចំពោះទំនិញដែលប្រើបានយូរ ដូចមុនទៀតទេ។ ការនាំចូលរថយន្តអ្នកធ្វើដំណើរក្នុងឆ្នាំ២០១៩ គឺបានត្រឹម ១៣,៩ភាគរយ ថយចុះពី ៧២,៤ភាគរយ ក្នុងឆ្នាំ២០១៨។ ក្នុងខែមករា ឆ្នាំ២០២០ ការនាំចូលទោចក្រយានយន្ត ថយចុះ ៦,៣ភាគរយ ប្រៀបទៅនឹងមួយឆ្នាំមុន ខណៈដែលទំនិញអេឡិកត្រូនិក ដូចជាទូរសព្ទចល័ត និងទូរទស្សន៍ ជាដើម បានថយចុះអស់ ៩,៩ភាគរយ។ អតិផរណាឡើងមួយក្រឹត កើនដល់ ៣,ភាគរយគិតត្រឹមចុងឆ្នាំ២០១៩ ប្រៀបទៅនឹង ១,៦ភាគរយ នាចុងឆ្នាំ២០១៨។

តម្លៃសរុបនៃគម្រោងវិនិយោគដោយផ្ទាល់ពីបរទេស ដែលទទួលបានការអនុម័តរួច ស្រុតចុះអស់ ៩,៦ភាគរយ ក្នុងឆ្នាំ២០១៩។ ប្រហែលជា ៤០ភាគរយ នៃលំហូរចូលរបស់ការវិនិយោគដោយផ្ទាល់ពីបរទេស បានមកពីប្រទេសចិន។ ដោយសារតែទុនហូរចូលយឺតជាងមុន អត្រាប្តូរប្រាក់ក៏ធ្លាក់ថ្លៃបន្តិចដែរ គឺក្នុងកម្រិត ៤០៧៥រៀលក្នុងមួយដុល្លារអាមរិក គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ កើនពី ៤០១៨រៀលក្នុងមួយដុល្លារ នាចុងឆ្នាំ២០១៨។ កំណើននៃចរាចរណ៍សាច់ប្រាក់ទូទៅក៏ថយចុះគួរឱ្យកត់សម្គាល់ដែរ មកនៅត្រឹម ១៨ភាគរយ ក្នុងឆ្នាំ២០១៩ ប្រៀបទៅនឹង២៤ភាគរយ ក្នុងឆ្នាំ២០១៨។ កំណើនបញ្ញើរូបិយវត្ថុអន្តរជាតិ រួញអស់១៥ភាគរយក្នុងឆ្នាំ២០១៩ ពី២៦,៨ភាគរយក្នុងឆ្នាំ២០១៨។ ស្រដៀងគ្នានេះ ឥណទានរបស់ធនាគារដល់វិស័យឯកជន (៩៥,៨ភាគរយនៃផ.ស.ស) បានថយកំណើនមកនៅត្រឹម២១,៣ភាគរយក្នុងឆ្នាំ២០១៩ ប្រៀបធៀបទៅនឹង២៤,២ភាគរយក្នុងឆ្នាំ២០១៨។ ធនបម្រុងអន្តរជាតិកើនជាលំដាប់ដល់ ១៨,៧ប៊ីលានដុល្លារអាមេរិក (ស្មើនឹងតម្លៃនៃការនាំចេញប្រហែល៧ខែ)។ ឱនភាពគណីចរន្តត្រូវបានប៉ាន់ស្មាន

ថានៅរក្សាស្ថិរភាពបាន ក្នុងកម្រិត៨,៨ភាគរយនៃផ.ស.ស ក្នុងឆ្នាំ២០១៩។

ដោយសារតែការគ្រប់គ្រងចំណូលមានភាពប្រសើរ និងសកម្មភាពសេដ្ឋកិច្ចរឹងមានសភាពខ្លាំងក្លា ចំណូលសរុបរបស់រដ្ឋ (រាប់ទាំងជំនួយឥតសំណង) ឡើងខ្ពស់ក្នុងឆ្នាំកន្លងទៅ គឺមានសរុបរហូតដល់ ២៥,៤ភាគរយនៃផ.ស.ស ពី២៣,៨ភាគរយក្នុងឆ្នាំ ២០១៨។ ការចំណាយរបស់រដ្ឋាភិបាលក៏កើនដែរ រហូតដល់ទៅជិត ២៥ភាគរយនៃផ.ស.ស ក្នុងឆ្នាំ២០១៩ ប្រៀបទៅនឹង២៣,៤ភាគរយ ក្នុងឆ្នាំ២០១៨ ដែលភាគច្រើនបណ្តាលមកពីការកើននៃចំណាយចរន្ត។ ជាលទ្ធផល តារាងសមតុល្យបង្ហាញឱ្យឃើញថាកម្ពុជាមានអតិរេកថវិកា (ប្រហែល០,៥ភាគរយនៃផ.ស.ស) នៅក្នុងឆ្នាំ២០១៩នេះ ដែលជាឆ្នាំលើកទីពីរហើយ។

## ចក្ខុវិស័យ

តាមការព្យាករណ៍ទុក កំណើនជាក់ស្តែងនឹងស្រុតចុះយ៉ាងគំហុក មកនោះត្រឹម២,៥ភាគរយ ក្នុងឆ្នាំ២០២០ តែវានឹងស្តារឡើងវិញមកនៅ៥,៩ភាគរយ ក្នុងឆ្នាំ ២០២១ ក្នុងសេណារីយោខ្សែបន្ទាត់គោល។ វិស័យទេសចរណ៍បានរងការប៉ះទង្គិចយ៉ាងដំណំពីការផ្ទុះវីរុសកូវីឌ-១៩។ ស្រដៀងគ្នានេះដែរ ឧស្សាហកម្មកាត់ដេរកំពុងប្រឈមនឹងវិបត្តិនៃការធ្លាក់ចុះតម្រូវការទូទាំងសាកលលោក ព្រមទាំងសម្ពាធបណ្តាលមកពីការដកចេញដោយអន្លើ នូវភាពអនុគ្រោះពាណិជ្ជកម្មក្រោមប្រព័ន្ធ «ទំនិញគ្រប់មុខលើកលែងតែអាវុធ» (EBA) របស់សហភាពអឺរ៉ុប។ ប្រសិនបើផលប៉ះទង្គិចនេះហៀរទៅដល់វិស័យសំណង់ និងអចលនទ្រព្យ — ដែលជាផ្នែកសំខាន់ៗនាំមកនូវកំណើនសេដ្ឋកិច្ចរបស់កម្ពុជា — ក្នុងខណៈដែលទីផ្សារហិរញ្ញវត្ថុមានចលាចល វាអាចនឹងជះឥទ្ធិពលអាក្រក់មែនទែនដល់កំណើនរបស់កម្ពុជា។ ការស្ទុះងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចនៅប្រទេសចិន និងនៅទីផ្សារធំៗផ្សេងទៀតក្នុងឆ្នាំ២០២១ នឹងធ្វើឱ្យចក្ខុវិស័យសេដ្ឋកិច្ចរបស់កម្ពុជា មានភាពប្រសើរឡើងវិញ នៅឆ្នាំក្រោយ។

ភាពក្រីក្រត្រូវបានរំពឹងថានឹងបន្តកាត់បន្ថយទៀត ប៉ុន្តែក្នុងល្បឿនមួយយឺតជាងមុន។ ដោយសារវិស័យកសិកម្មជាប្រភពរបរចិញ្ចឹមជីវិតដ៏សំខាន់របស់ជនក្រីក្រភាគច្រើន កិច្ចខិតខំប្រឹងប្រែងធ្វើពិពិធកម្មក្នុងវិស័យនេះ និងប្រភពចំណូលរបស់គ្រួសារនៅជនបទ ព្រមទាំងការលើកកម្ពស់ការកែច្នៃកសិផល ត្រូវបានរំពឹងទុកថានឹងជួយសម្រាលការលំបាករបស់ជនក្រីក្រ នៅក្នុងរយៈពេលមធ្យមបាន។

## ហានិភ័យ និងបញ្ហាប្រឈម

ហានិភ័យចំពោះចក្ខុវិស័យកំណើនរបស់កម្ពុជា នាពេលខាងមុខ រួមមាន ការបន្តធ្លាក់ចុះនូវភ្ញៀវទេសចរដោយមកការផ្ទុះមេរោគនេះនៅអូសបន្លាយយូរ, សកម្មភាពសេដ្ឋកិច្ចសាកលលោកក្រងើបឡើងវិញ ដែលកាន់តែតែធ្វើឱ្យវិស័យឧស្សាហកម្មនៅកម្ពុជាលែងសូវមានសកម្មភាព ពីព្រោះខ្វះតម្រូវការសម្រាប់ការនាំចេញសម្លៀកបំពាក់ និងការធ្លាក់ចុះគំហុកនៃការវិនិយោគដោយផ្ទាល់ពីបរទេស ដោយមកពីចលាចលលើទីផ្សារហិរញ្ញវត្ថុអូសបន្លាយ ហើយសកម្មភាពសំណង់ក៏អត់ងើបរួចដែរ។ នៅក្នុងសេណារីយោបែបនេះ កំណើនជាក់ស្តែងត្រូវបានព្យាករថានឹងស្រុតមកនៅត្រឹម ១ភាគរយប៉ុណ្ណោះ ក្នុងឆ្នាំ ២០២០ មុននឹងងើបមកនៅ ៣,៩ភាគរយវិញ ក្នុងឆ្នាំ ២០២១។ ភាពងាយរងគ្រោះផ្សេងទៀតដែលអាចជាហានិភ័យដែរនោះ រួមមាន ការផ្ទុះទ្រង់ទ្រាយធំនូវកូវីឌ-១៩ក្នុងប្រទេស, ការប្រែប្រួលស្ថានភាពទីផ្សារអចលនទ្រព្យ បន្ទាប់ពីការរីកដុះដាលផ្នែកសំណង់ និងការជួញដូរដីធ្លីពុះកញ្ជ្រោលអស់រយៈពេលជាច្រើនឆ្នាំមកហើយ, កំណើនក្នុងការផ្តល់ឥណទានដល់វិស័យសំណង់/អចលនទ្រព្យ/ការទិញដោយបង់រម្លស់ (នៅពេលដែលវិស័យទាំងនេះពឹងផ្អែកយ៉ាងខ្លាំង លើការវិនិយោគពីប្រទេសចិន), និងកម្ចីដែលមិនទាន់បានទូទាត់នៅក្នុងកម្រិតខ្ពស់នៅឡើយ។

នៅក្រោមកញ្ចប់ថវិកាឆ្នាំ២០២០ រាជរដ្ឋាភិបាលបានដាក់ចេញវិធានការហិរញ្ញវត្ថុមួយចំនួន សម្រាប់សម្រាលផលប៉ះទង្គិចអវិជ្ជមានមកលើសេដ្ឋកិច្ច។ ទោះជាពេលនេះគេមិនអាចនិយាយអំពីប្រសិទ្ធភាពបាននៅឡើយក្តី វិធានការជួយជ្រោមជ្រែងតាមរយៈការអនុគ្រោះពន្ធ ដល់បណ្តាឧស្សាហកម្មដែលរងផលប៉ះទង្គិចធ្ងន់ធ្ងរ និងកម្មវិធីបង្កើនជំនាញដល់កម្មករដែលបាត់បង់ការងារ អាចជួយបានខ្លះដែរ។ ការចាក់បញ្ចូលទុនបន្ថែមទៀតទៅឱ្យធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃកសិផល និងកែលម្អយន្តការសម្រួលពាណិជ្ជកម្ម ស្របគ្នានឹងការពង្រីក«គន្លងបៃតង» និងការបញ្ចេញទំនិញក្រោយការធ្វើសវនកម្ម នឹងកាន់តែជួយពង្រឹងពង្រីកសមត្ថភាពប្រកួតប្រជែង យូរអង្វែងទៅមុខទៀត។ ក្រៅពីនេះ ចាំបាច់នៅមានកិច្ចការរៀបចំដែលត្រូវធ្វើថែមទៀត នៅពីក្រោយការផ្តួចផ្តើមផ្សេងទៀត មានដូចជា ការបង្កើតធនាគារថ្មីមួយសម្រាប់ជួយគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម ទន្ទឹមគ្នានឹងការផ្តល់ហិរញ្ញប្បទានរួម និងសកម្មភាពចែករំលែកការយល់ដឹងអំពីហានិភ័យជាមួយធនាគារពាណិជ្ជកម្ម (និងស្ថាប័នមីក្រូហិរញ្ញវត្ថុ) ដើម្បីបង្កើនលទ្ធភាពរកបានប្រភពហិរញ្ញវត្ថុសម្រាប់ធ្វើអាជីវកម្ម។ អ្វីដែលចាំបាច់ត្រូវដាក់ចេញដែរនោះ គឺវិធានការនានាសម្រាប់ឆ្លើយតបទៅនឹងទិដ្ឋភាពសំខាន់ៗ នៅពីក្រោយការសម្រួលការធ្វើអាជីវកម្ម។ ការកែលម្អការគ្រប់គ្រងផ្នែកសារពើពន្ធ និងការវិនិយោគសាធារណៈ ត្រូវតែបន្តធ្វើទៅមុខ ដើម្បីធានាឱ្យការអនុវត្តកញ្ចប់ថវិកាទ្រទ្រង់សេដ្ឋកិច្ចនេះ ប្រព្រឹត្តមានប្រសិទ្ធភាព។

ក្នុងកាលៈទេសៈនេះ សំខាន់ណាស់ដែលគេត្រូវអនុវត្តវិធានការប្រយ័ត្នប្រយែងផ្នែកម៉ាក្រូសេដ្ឋកិច្ច មានដូចជា ការកម្រិតការផ្តល់កម្ចីធនាគារដល់ផ្នែកសំណង់ និងអចលនទ្រព្យ ហើយរឹតបន្តឹងអត្រារវាងការខ្ចីនិងតម្លៃអចលនទ្រព្យ លើកលែងចំពោះតែករណីអតិថិជនទិញលើកដំបូង ទាំងអស់នេះជាប្រយោជន៍ជួយបន្ធូរផលប៉ះទង្គិច ដែលអាចកើត

មាន ដោយសារតែការប្រែប្រួលរបស់ទីផ្សារ អចលនទ្រព្យ។ វិធានការផ្ទេករូបិយវត្ថុដែលបានដាក់ចេញនាពេលថ្មីៗនេះ រួមមានការកាត់បន្ថយអត្រាតម្រូវការនៃប្រាក់តម្កល់, អត្រាកម្រិតគោល និងផលធៀបវិសាលភាពគ្រប់ដណ្ដប់របស់សាច់ប្រាក់។

គំនូសតាង១៖ សមាសភាគដែលមានចំណែកដល់កំណើនជាក់ស្តែងនៃផ.ស.ស




ប្រភព៖ អាជ្ញាធរកម្ពុជា និងការប៉ាន់ប្រមាណដោយបុគ្គលិក

គំនូសតាង២៖ ទីផ្សារសម្រាប់ការនាំចេញពីកម្ពុជា នូវផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ការធ្វើដំណើរ (ភាគរយប្រែប្រួល ឆ្នាំ/ឆ្នាំ)




ប្រភព៖ អាជ្ញាធរកម្ពុជា
Note: RoW = The Rest of the World.

**តារាង២៖ កម្ពុជា -- សូចនាករនៃចក្ខុវិស័យស្តីពីទិដ្ឋភាពម៉ាក្រូនៃភាពក្រីក្រ ក្រោមសេណារីយោបន្ទាត់គោល**
(ការប្រែប្រួលប្រចាំឆ្នាំគិតជាភាគរយ ដែលមិនទាន់មានការបញ្ជាក់ផ្ទុយពីនេះ)

| | 2017 | 2018 | 2019pre | 2020p | 2021f | 2022f |
|---|---|---|---|---|---|---|
| **កំណើនផ.ស.សជាក់ស្តែង គិតតាមតម្លៃថេរលើទីផ្សារ** | 7.0 | 7.5 | 7.1 | 2.5 | 5.9 | 6.3 |
| ការទទួលទានប្រើប្រាស់ជាឯកជន | 3.7 | 3.0 | 7.0 | 4.9 | 5.0 | 5.4 |
| ការប្រើប្រាស់របស់រដ្ឋាភិបាល | 23.5 | 5.1 | -9.1 | 1.3 | 17.1 | 9.5 |
| ការវិនិយោគជនថេរសរុប | 6.1 | 6.1 | 10.7 | -2.2 | 7.4 | 7.2 |
| ការនាំចេញ ទំនិញ និងសេវា | 5.3 | 5.3 | 7.8 | 2.6 | 7.0 | 7.5 |
| កានាំចូល ទំនិញ និងសេវា | 4.1 | 4.1 | 6.0 | 3.0 | 6.9 | 7.1 |
| **កំណើនផ.ស.សជាក់ស្តែង គិតតាមតម្លៃថេររបស់កត្តានីមួយៗ** | 6.8 | 7.4 | 6.8 | 2.4 | 6.0 | 6.3 |
| កសិកម្ម | 1.7 | 1.1 | -0.5 | 0.3 | 0.4 | 0.5 |
| ឧស្សាហកម្ម | 9.7 | 11.6 | 11.3 | 7.5 | 9.2 | 9.3 |
| សេវាកម្ម | 7.0 | 6.8 | 6.2 | -1.4 | 5.3 | 5.6 |
| **អតិផរណា (សន្ទស្សន៍ថ្លៃទំនិញ)** | 3.3 | 3.1 | 3.2 | 2.3 | 2.0 | 2.1 |
| **សមតុល្យគណនីចរន្ត (%នៃផ.ស.ស)** | -9.7 | -8.9 | -8.8 | -10.9 | -11.9 | -12.8 |
| **ការវិនិយោគផ្ទាល់ពីបរទេសសរុប (%នៃផ.ស.ស)** | 12.1 | 12.6 | 10.6 | 9.0 | 9.1 | 9.3 |
| **សមតុល្យបញ្ជីសារពើពន្ធ (%នៃផ.ស.ស)** | -0.8 | 0.4 | 0.5 | -3.0 | -0.4 | -0.6 |
| **បំណុល (%នៃផ.ស.ស)** | 30.3 | 30.0 | 30.0 | 32.2 | 33.4 | 33.0 |
| **សមតុល្យបឋម (%នៃផ.ស.ស)** | -0.4 | 0.8 | 0.9 | -2.5 | 0.1 | -0.1 |

ប្រភព៖ Macro Poverty Outlook and official data.

Notes: p = projection, pre = preliminary, and f = forecast.